បងឆ្មា និងបងឆ្កែ៖ បាត់បងឆ្មាទៅណាហើយ

Elke and René Leisink

René & Elke Leisink

letsreadasia.org

នេះជាផ្ទះរបស់បងឆ្មា។



នេះគឺជាបងឆ្កែ។

បងឆ្កែដើរទៅផ្ទះរបស់បងឆ្មា។ បងឆ្កែ
ឃើញទ្វារចំហ។ ទ្វារផ្ទះរបស់បងឆ្មា
ចំហ។

បងឆ្កែដើរចូលទៅក្នុង។ ពេលនេះ បងឆ្កែនៅខាងក្នុងផ្ទះ។ ពេលនេះ បងឆ្កែនៅខាងក្នុងផ្ទះរបស់បងឆ្មា។

តែបងឆ្មាអត់នៅផ្ទះទេ។ អូ! អូ! តើបាត់
បងឆ្មាទៅណាហើយ?

បងឆ្កែរកមើលលើគ្រែ តែបងឆ្មាមិននៅ
លើគ្រែទេ។



បងឆ្កែរកមើលក្រោមតុ តែបងឆ្មាមិន
នៅក្រោមតុទេ។

បងឆ្កែរកមើលខាងមុខកៅអី តែបងឆ្មា
មិននៅខាងមុខកៅអីទេ។

បងឆ្កែរកមើលខាងក្រោយទ្វារ តែបងឆ្មា
មិននៅខាងក្រោយទ្វារទេ។

ពេលនោះបងឆ្កែឃើញជណ្ដើរមួយ។ បងឆ្កែឃើញជណ្ដើរមួយនៅជាប់នឹងដើមឈើ។ ជណ្ដើរនោះបាក់បាត់ទៅហើយ។

បងឆ្កែងើយមើលទៅលើ។ បងឆ្កែ
ងើយមើលទៅលើដើមឈើ។ បងឆ្កែ
ងើយមើលស្លឹកឈើនៅលើដើមនោះ។

បងឆ្កែឃើញជើងមួយគូ។ មានជើង
មួយគូចេញមកតាមស្លឹកឈើ។ ហើយ
បងឆ្កែឃើញដៃមួយ។ មានដៃមួយ
ចេញមកតាមស្លឹកឈើ។ ហើយ
បន្ទាប់មក បងឆ្កែឃើញមុខ...

បងឆ្កែឃើញមុខរបស់បងឆ្មា! បងឆ្មាកំពុងអង្គុយលើដើមឈើ។ បងឆ្មាកំពុងអង្គុយលើដើមឈើ ដោយមានបាល់មួយផង។ បងឆ្មាមិនអាចចុះពីលើដើមឈើបានទេ។ បងឆ្មាមិនអាចចុះពីលើដើមឈើបានទេ ដោយសារជណ្ដើរបានបាក់ទៅហើយ។

បងឆ្កែជួយបងឆ្មា។ បងឆ្កែជួយបងឆ្មា
ចុះពីលើដើមឈើ។

ពេលចុះដល់ក្រោម បងឆ្មាថើបបងឆ្កែមួយខ្សឺត។

លាហើយ បងឆ្មា។ លាហើយ បងឆ្កែ។

Brought to you by

The Asia Foundation

Let's Read! is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia. booksforasia.org

To read more books like this and get further information about this book, visit letsreadasia.org

Original Story
Cat & Dog: Where Is Cat, author: Elke and René Leisink. illustrator: by René & Elke Leisink. Published by Biblionef, http://cat-and-dog.org/ © Biblionef. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by/4.0/

Contributing translators: Wanna Net